# តំបន់សេដ្ឋកិច្ចពិសេសនៅខេត្តព្រះសីហនុ

*បណ្ឌិត* **ឈឿន ប៊ុនឆា**
*មន្ត្រីខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យប្រធាន*
*រាជបណ្ឌិត្យសភាកម្ពុជា*

## ១. សេចក្តីផ្តើម

*ខេត្តព្រះសីហនុជាខេត្តមួយស្ថិតនៅភាគនិរតី (ខាងត្បូង) នៃប្រទេសកម្ពុជា ជាប់នឹងឈូងសមុទ្រថៃ។ ខេត្តព្រះសីហនុមានប្រជាជនប្រមាណសរុប ៣០៣ ០០០ នាក់[១]។ បច្ចុប្បន្ន ខេត្តព្រះសីហនុមានទំហំជាង ២ ៦០០គីឡូម៉ែត្រក្រឡា មានកោះទាំងធំទាំងតូចចំនួន២៣ ហើយឆ្នេរសមុទ្រប្រវែងជាជាង១៧០គីឡូម៉ែត្រ។ ជាពិសេស ខេត្តនេះមានកំពង់ផែស្វ័យតក្រុងព្រះសីហនុ ដែលជាច្រកទ្វារសេដ្ឋកិច្ចមួយដ៏សំខាន់ ដើម្បីបើកផ្លូវឱ្យកម្ពុជាធ្វើពាណិជ្ជកម្មអន្តរជាតិតាមសមុទ្រប្រកបដោយសក្តានុពល។ កំពង់ផែក្រុងព្រះសីហនុ គឺជាកំពង់ផែទឹកជ្រៅតែមួយគត់នៅកម្ពុជា ដែលមានស្ថានីយ៍ប្រេងកាត និងសុខុបត្ថម្ភវត្ថុដឹកជញ្ជូនភស្តុភារ។ ជាមួយគ្នានេះ គឺជាតំបន់ដែលមានហេដ្ឋារចនាសម្ព័ន្ធល្អ និងការទំនាក់ទំនងពាណិជ្ជកម្មមានភាពងាយស្រួល។ ដោយហេតុថានៅទីនេះមានកំពង់ផែទឹកជ្រៅ និងអាកាសយានដ្ឋានអន្តរជាតិ ខេត្តព្រះសីហនុ ត្រូវបានសម្តេចអគ្គមហាសេនាបតីតេជោ* ***ហ៊ុន សែន*** *អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់រហស្សនាមឱ្យខេត្តព្រះសីហនុ ថាជាខេត្តអភិវឌ្ឍពហុជាតិសាសន៍ ដែលជាប៉ូលសេដ្ឋកិច្ចមួយដ៏មានសក្តានុពលសម្រាប់ប្រទេសកម្ពុជា ព្រមទាំងជាខេត្តមួយបាននិងកំពុងទាក់ទាញបណ្តាអ្នកវិនិយោគក្នុងស្រុក និងក្រៅស្រុកយ៉ាងច្រើននៅទីនោះ។*

*តួយ៉ាង តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ គឺជាឧទ្យានឧស្សាហកម្មធំបំផុតរបស់កម្ពុជា បាននិងកំពុងឈានទៅមុខក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។*

---

[១] *ជំរឿនជាផ្លូវការរបស់ក្រសួងផែនការ* ឆ្នាំ២០១៩។

តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៨ ដែលអភិវឌ្ឍនៅលើផ្ទៃដីទំហំប្រមាណសរុប ១ ១០០ ហិកតានៅលើតំបន់ខ្ពង់រាប ភាគខាងកើតនៃក្រុងព្រះសីហនុ និងនៅកំពង់ផែសមុទ្រទឹកជ្រៅ ដោយការអភិវឌ្ឍ និងប្រតិបត្តិការរួមគ្នាជាមួយបណ្តាក្រុមហ៊ុនចិន (Jiangsu Taihu Cambodia International Economic Cooperation Investment Co Ltd) និងក្រុមហ៊ុនអភិវឌ្ឍន៍វិនិយោគអន្តរជាតិកម្ពុជា (CIIDG)។

## ២. តំបន់សេដ្ឋកិច្ចពិសេស

### ២.១. និយមន័យ

ពាក្យ "**តំបន់សេដ្ឋកិច្ចពិសេស**" (Special Economic Zone/SEZ) សំដៅលើតំបន់ទាំងឡាយណា ដែលមានលក្ខខណ្ឌវិនិយោគដាច់ដោយឡែកពីបទបញ្ញត្តិ ឬច្បាប់របស់រដ្ឋត្រូវបានអនុវត្តនៅតំបន់ទូទៅ[២]។ លក្ខណៈដោយឡែកនេះហើយដែលគេឱ្យឈ្មោះថា "ពិសេស"។ ជាធម្មតា បទបញ្ញត្តិនានានៅក្នុងវិស័យវិនិយោគនៃតំបន់សេដ្ឋកិច្ចពិសេស ច្រើនតែដាក់ឱ្យអនុវត្តចំពោះបណ្តាវិនិយោគិនបរទេសដែលបានបណ្តាក់ទុននៅក្នុងប្រទេសណាមួយ។ ការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស បង្កលក្ខណៈងាយស្រួលសម្រាប់អ្នកវិនិយោគ ទទួលបានការអនុគ្រោះពន្ធអាករ និងការបង់ពន្ធនាំចេញឬនាំចូលទាបជាងកម្រិតទូទៅ[៣]។ ភាគច្រើនតំបន់សេដ្ឋកិច្ចពិសេសត្រូវបានបង្កើតឡើងដើម្បីទាក់ទាញអ្នកវិនិយោគបរទេសទៅបណ្តាក់ទុននៅក្នុងប្រទេសដែលបង្កើតតំបន់នេះ។

តំបន់សេដ្ឋកិច្ចពិសេស ជាឧបករណ៍សេដ្ឋកិច្ចដ៏សំខាន់ ដែលត្រូវបានអនុវត្តដើម្បីទទួលបាននូវលទ្ធផលផ្សេងៗគ្នា ដោយប្រើប្រាស់នូវមធ្យោបាយក៏ផ្សេងៗគ្នាផងដែរ។

### ២.២. គោលបំណង

វត្ថុបំណងសំខាន់នៃការបង្កើតតំបន់សេដ្ឋកិច្ចពិសេស គឺដើម្បីទាក់ទាញអ្នកវិនិយោគពីក្រៅស្រុកឱ្យទៅវិនិយោគនៅក្នុងតំបន់ឬប្រទេសណាមួយ។ ពីព្រោះការវិនិយោគផ្ទាល់ពីក្រៅប្រទេស (Foreign Direct Investment/ FDI) មានសារៈប្រយោជន៍សម្រាប់ស្រូបទាញទុន

[២] **តំបន់សេដ្ឋកិច្ចពិសេស និងការទាញយកតម្លៃពីតំបន់មេគង្គ** ករណីសិក្សាឆ្នាំ២០១៧។

[៣] **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រដ្ឋាភិបាលកម្ពុជា** ឆ្នាំ២០១៤-២០១៨។

បន្ថែមលើវិនិយោគិននៅក្នុងស្រុកដែលមានស្រាប់។ វត្ថុបំណងសំខាន់មួយទៀតគឺដើម្បីបង្កលក្ខណៈល្អប្រសើរសម្រាប់ប្រទេសមួយប្រកួតប្រជែងខាងទំនិញ/សេវាកម្ម និងតម្លៃទល់នឹងប្រទេសដទៃនៅលើទីផ្សារក្នុងតំបន់និងទីផ្សារអន្តរ-ជាតិ ជាពិសេសផ្តោតលើការនាំចេញ។

ជាមួយគ្នានេះ ក្របខណ្ឌច្បាប់ និងអភិបាលកិច្ចនៃតំបន់សេដ្ឋកិច្ចពិសេសនីមួយៗត្រូវបានកែសម្រួល ដើម្បីឱ្យមានភាពប្រដំប្រសងគ្នារវាងផលប្រយោជន៍អ្នកវិនិយោគ និងប្រជាជនមូលដ្ឋានប្រកបដោយនិរន្តរភាព។ ជាក់ស្តែង ការបង្កើតនិងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសនៅខេត្តព្រះសីហនុ ដែលជាតំបន់សេដ្ឋកិច្ចជាប់មាត់សមុទ្រមួយដ៏សំខាន់ក្នុងភាគនិរតីនៃប្រទេសកម្ពុជា។

## ៣. ការគ្រប់គ្រងនិងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស

### ៣.១. រចនាសម្ព័ន្ធតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

តំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានរចនាសម្ព័ន្ធដឹកនាំគ្រប់គ្រង និងអភិវឌ្ឍដោយក្រុមប្រឹក្សាភិបាលតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ដែលមាននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រធាន។




### ៣.២. គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេស

គណៈកម្មាធិការដោះស្រាយបញ្ហានៃតំបន់សេដ្ឋកិច្ចពិសេស មានភារកិច្ចដោះស្រាយ ជាបន្ទាន់នូវរាល់កិច្ចការទាំងឡាយដែលកើតមាននៅតាមតំបន់សេដ្ឋកិច្ចពិសេសទាំងលើទិដ្ឋភាពបច្ចេកទេស ទិដ្ឋភាពច្បាប់ ដែលមានលក្ខណៈស្ថិតក្នុងសមត្ថកិច្ចចំរុះត្រូវដោះស្រាយដោយអន្តរក្រសួងឬអន្តរស្ថាប័ន ហើយដែលហួសពីលទ្ធភាពសម្រេចរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ឬរបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។

ក្រៅពីនោះ គណៈកម្មាធិការដោះស្រាយបញ្ហាតំបន់សេដ្ឋកិច្ចពិសេសក៏ទទួលភារកិច្ច ជាយន្តការទទួលពាក្យតវ៉ា និងដោះស្រាយសំណើតវ៉ាពីសំណាក់

អ្នកអភិវឌ្ឍតំបន់ និងអ្នកវិនិយោគក្នុងតំបន់ផងដែរ។ គណៈកម្មាធិការនេះមានទីតាំងនៅទីស្នាក់ការក្រុមប្រឹក្សា និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាក្នុងកិច្ចការងាររបស់ខ្លួន។ សមាសភាពរបស់គណៈកម្មាធិការដោះស្រាយបញ្ហានៃតំបន់សេដ្ឋកិច្ចពិសេសមានដូចតទៅៈ

១- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ជាសហប្រធាន)

២- រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី (ជាសមាជិក)

៣- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (សមាជិក)

៤- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម (សមាជិក)

៥- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ (សមាជិក )

៦- រដ្ឋមន្ត្រីក្រសួងបរិស្ថាន (សមាជិក)

៧- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (សមាជិក)

៨- រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន (សមាជិក)

៩- រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (សមាជិក)

១០- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (សមាជិក)

១១- អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា (ជាលេខាធិការ)។

ក្នុងករណីចាំបាច់ គណៈកម្មាធិការនេះអាចអញ្ជើញសមាជិកណាមួយនៃក្រុមប្រឹក្សា ដើម្បីចូលរួមប្រជុំរាល់កិច្ចប្រជុំរបស់គណៈកម្មាធិការនេះ។ សម័យប្រជុំរបស់គណៈកម្មាធិការដោះស្រាយបញ្ហាតំបន់សេដ្ឋកិច្ចពិសេសប្រព្រឹត្តទៅតាមការកោះអញ្ជើញប្រជុំរបស់លេខាធិការនៃគណៈកម្មាធិការដោះស្រាយបញ្ហានៅតំបន់សេដ្ឋកិច្ចពិសេសផ្អែកតាមការកំណត់ និងការណែនាំរបស់សហប្រធាននៃគណៈកម្មាធិការនេះ។

### ៣.៣. តួនាទីភារកិច្ចរបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេស

ចំពោះគណៈកម្មាធិការនៃតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ជាច្រកចេញ-ចូលតែមួយក្នុងការទទួលបន្ទុកលើការអភិវឌ្ឍ ការគ្រប់គ្រងនិងការត្រួតពិនិត្យនៃកិច្ចដំណើរការរបស់តំបន់សេដ្ឋកិច្ចពិសេស។ ភារកិច្ចរបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា រួមមានៈ

១) ធ្វើជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើរាល់ការងារពាក់ព័ន្ធនឹងគោល

នយោបាយយុទ្ធសាស្ត្រលើកគម្រោងផែនការ និងកំណត់ទិសដៅសម្រាប់ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២) កំណត់គោលការណ៍ និងបទប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធដល់ការងារតែងតាំងរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ការចាត់តាំងយន្តការច្រក-ចេញចូលតែមួយនៅក្នុងតំបន់ ការគ្រប់គ្រងកិច្ចការរដ្ឋបាលទូទៅនៃដំណើរការរបស់តំបន់ក្នុងការដោះស្រាយទំនាស់និងការរំលាយតំបន់ដោយថាហេតុ។

៣) អនុវត្តផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធ និង មិនមែនសារពើពន្ធដល់អ្នកអភិវឌ្ឍតំបន់ និងណែនាំគោលការណ៍នៃការលើកទឹកចិត្តរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសសម្រាប់ផ្តល់ជូនដល់អ្នកវិនិយោគក្នុងតំបន់ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៤) រៀបចំគោលការណ៍ណែនាំអំពីការងារគ្រប់គ្រង និងការបណ្តុះបណ្តាលពលករ ការងារបរិស្ថាន ការងារសំណង់ការនាំចេញ នាំចូល ការទទួលបាននូវការលើកទឹកចិត្តវិនិយោគ និងកិច្ចការជំនាញផ្សេងៗ ទៀតរួមទាំងការបង្កលក្ខណៈងាយស្រួលក្នុងកិច្ចទំនាក់ទំនងជាមួយក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដើម្បីជានាឱ្យកិច្ចការរបស់តំបន់សេដ្ឋកិច្ចពិសេសប្រព្រឹត្តទៅមានភាពរលូន និងមានប្រសិទ្ធភាព។

៥) ធ្វើការងារអធិការកិច្ចលើរាល់សកម្មភាពមិនប្រក្រតីរបស់តំបន់។

៦) ដោះស្រាយរាល់សំណូមពរពាក់ព័ន្ធនឹងផលប្រយោជន៍របស់អ្នកអភិវឌ្ឍតំបន់ អ្នកវិនិយោគក្នុងតំបន់ កម្មករនិយោជិត និយោជក និងបញ្ហាសំណូមពរបច្ចេកទេសនិងច្បាប់ផ្សេងៗ។

**៣.៤. អំពីរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស**

រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសគឺជាយន្តការច្រកចេញចូលតែមួយ ដែលរៀបចំដោយគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ដើម្បីប្រចាំការជាអចិន្ត្រៃយ៍នៅតាមតំបន់សេដ្ឋកិច្ចពិសេសនីមួយៗ និងមានរចនាសម្ព័ន្ធនិងរបបការងារដូចតទៅ។ សមាសភាពរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ដូចខាងក្រោម៖

តំណាងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា (ជាប្រធាន)។

តំណាងទីចាត់ការគយនិងរដ្ឋាករកម្ពុជា (ជាសមាជិក)។

តំណាងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនាំចេញ-នាំចូល និងបង្ក្រាបការក្លែងបន្លំ (សមាជិក)។

តំណាងរបស់ក្រសួងពាណិជ្ជកម្ម (សមាជិក)។

តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (សមាជិក)។

១) សមាសភាពមន្ត្រីខាងលើនេះត្រូវតែងតាំងដោយក្រសួង ស្ថាប័នសាមីដើម្បីឱ្យទៅប្រចាំការជាអចិន្ត្រៃយ៍នៅតាមតំបន់នីមួយៗនៅពេលដែលតំបន់នោះចាប់ផ្តើមដំណើរការ។

២) ការិយាល័យធ្វើការងាររបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសគឺជាបន្ទុករបស់អ្នកអភិវឌ្ឍតំបន់ក្នុងការផ្តល់ឱ្យនូវការិយាល័យធ្វើការ ដោយផ្គត់ផ្គង់សម្ភារៈប្រើប្រាស់ ទឹក ភ្លើង កន្លែងសម្រាក និងការឧបត្ថម្ភនានាទៅតាមលទ្ធភាពជាក់ស្តែង។ល។

៣) គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធខាងលើ ត្រូវធ្វើប្រតិភូកម្មសិទ្ធិអំណាចគ្រប់គ្រាន់ជូនតំណាងរបស់ខ្លួនក្នុងការសម្រេចការងារជួសមុខឱ្យក្រសួង និងស្ថាប័នស្របទៅតាមសមត្ថកិច្ចរៀងៗខ្លួននៅក្នុងតំបន់។

៤) ប្រាក់បៀវត្សរបស់មន្ត្រីរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ត្រូវបើកនៅតាមអង្គភាពដើម។

៥) រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសនីមួយៗមានត្រាមួយដោយឡែកសម្រាប់ប្រើប្រាស់ជាផ្លូវការលើរាល់លិខិតស្នាមទាំងអស់ បម្រើឱ្យការងាររបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស។ ភារកិច្ចរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសគឺ

(ក) ត្រួតពិនិត្យតាមមុខជំនាញសមត្ថកិច្ចចំពោះការចេញពីនិងចូលមកនូវទំនិញ មធ្យោបាយ និងជនានុជនគ្រប់រូបរបស់តំបន់។ អនុវត្តការត្រួតពិនិត្យបែបបទគយសម្រាប់ការចេញចូលទំនិញ និងសម្រួលបែបបទរដ្ឋបាលដល់កិច្ចដំណើរការរបស់តំបន់ជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ចជំនាញនានា របស់រាជរដ្ឋាភិបាល។

(ខ) ត្រួតពិនិត្យការអនុវត្តការងាររបស់អ្នកអភិវឌ្ឍតំបន់ និង អ្នកវិនិយោគក្នុងតំបន់លើរាល់សកម្មភាពនៅក្នុងតំបន់ ដោយផ្អែកតាមគោលការណ៍ដែលបានកំណត់។

(គ) ពិនិត្យលើសំណើសុំចុះបញ្ជីវិនិយោគ ពិនិត្យផ្តល់ជូនការលើកទឹកចិត្ត ការចេញលិខិតអនុញ្ញាត អាជ្ញាបណ្ណ វិញ្ញាបនបត្រប្រភពដើមទំនិញដែលស្នើឡើងដោយអ្នកវិនិយោគក្នុងតំបន់ ដើម្បីធ្វើការសម្រេចជូនអ្នកវិនិយោគ ក្នុងតំបន់នៅនឹងកន្លែង។

(ឃ) ធ្វើការត្រួតពិនិត្យការងារសកម្មភាពតាមមុខជំនាញនៅក្នុងតំបន់។

(ង) សហការជាមួយអ្នកអភិវឌ្ឍតំបន់ ដោះស្រាយការងារដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន។

(ច) សម្រួលរាល់បែបបទដែលពាក់ព័ន្ធអោយបានឆាប់រហ័សនិងមានប្រសិទ្ធភាព។

(ឆ) ធ្វើរបាយការណ៍ការងារប្រចាំខែ ប្រចាំត្រីមាស ឆមាសនិងឆ្នាំពីសកម្មភាពរបស់តំបន់ជូនក្រសួង ស្ថាប័នគ្រប់គ្រងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង។

(ជ) ធ្វើកិច្ចការផ្សេងៗទៀតក្នុងការសម្របសម្រួលដោះស្រាយរាល់សំណើរបស់អ្នកវិនិយោគក្នុងតំបន់ ពាក់ព័ន្ធទៅនឹងបញ្ហាក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល។

## ៣.៥. លក្ខខណ្ឌអ្នកអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស

អ្នកអភិវឌ្ឍតំបន់ ធ្វើសកម្មភាពស្ថិតនៅក្រោមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ អ្នកអភិវឌ្ឍតំបន់មានភារកិច្ចៈ

(ក) ត្រូវមានទុននិងមធ្យោបាយគ្រប់គ្រាន់ ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់រួមទាំងធនធានមនុស្សដើម្បីដឹកនាំសកម្មភាពនៃតំបន់។

(ខ) ត្រូវមានដីធ្លី និងមានសិទ្ធិកាន់កាប់ច្បាប់ដើម្បីបង្កើតតំបន់។

(គ) ធ្វើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់រួមមានដូចជា ការសាងសង់ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹកស្អាត ប្រព័ន្ធផ្លូវគមនាគមន៍ ប្រព័ន្ធទូរគមនាគមន៍ ប្រព័ន្ធថែរក្សា និងគ្រប់គ្រងបរិស្ថាន រួមនៃតំបន់សាងសង់ឃ្លាំងផ្ទុកទំនិញ ស្ថានីយការពារអគ្គីភ័យនិងសំណង់សេវាកម្មផ្សេងៗទៀត ដែលជាតម្រូវការចាំបាច់នៅក្នុងតំបន់។

(ឃ) ជួលដី ផ្តល់សេវានានាដល់អ្នកវិនិយោគក្នុងតំបន់ កំណត់ថ្លៃឈ្នួលនិងថ្លៃសេវា។

ដែលបានផ្តល់ជូនអ្នកវិនិយោគក្នុងតំបន់ រួមមានដូចជាតម្លៃទឹក អគ្គិសនី

អាគារ ប្រព័ន្ធទូរគមនាគមន៍ អនាម័យតាមទីសាធារណៈរបស់តំបន់ កម្លាំងសន្តិសុខ និងមធ្យោបាយផ្សេងៗដែលទទួលបំរើដល់ដំណើរការប្រចាំថ្ងៃរបស់អ្នកវិនិយោគក្នុងតំបន់។

(ង) រៀបចំចាត់ចែងនូវកងកម្លាំងសន្តិសុខយាមកាម និងធានានូវសណ្តាប់ធ្នាប់ល្អនៅក្នុងតំបន់ជាប្រចាំ ២៤ម៉ោងលើ២៤ម៉ោង។

(ច) រៀបចំបទប្បញ្ញត្តិនានាដែលទាក់ទងដល់ការងារសេវាកម្មក្នុងតំបន់ រួមមានបទបញ្ជាផ្ទៃក្នុងតំបន់ វិន័យទូទៅរបស់អ្នកវិនិយោគក្នុងតំបន់ និងកំណត់មុខសញ្ញាអាជីវកម្ម ផលិតកម្ម សេវាកម្មដែលទទួលឱ្យបោះទីតាំងក្នុងតំបន់តាមគោលការណ៍កំណត់ឱ្យធ្វើសកម្មភាពក្នុងតំបន់។

(ឆ) ធ្វើការឃោសនាទាក់ទាញអ្នកវិនិយោគឱ្យមកធ្វើការវិនិយោគក្នុងតំបន់ និង ផ្តល់ព័ត៌មានលម្អិតស្តីពីបែបបទ នីតិវិធីនិងផលប្រយោជន៍ដែលអ្នកវិនិយោគត្រូវទទួលបានក្នុងការធ្វើវិនិយោគនៅក្នុងតំបន់របស់ខ្លួន។

(ជ) ធ្វើការថែទាំ និងជួសជុលបញ្ហាហេដ្ឋារចនាសម្ព័ន្ធ ធានាបាននូវគុណភាព និងអនាម័យត្រឹមត្រូវ និងទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់លើរាល់សកម្មភាពមិនប្រក្រតី និងការអនុវត្តខុសពីគោលការណ៍កំណត់របស់គណៈកម្មាធិការក្នុងតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។

(ឈ) ធ្វើរបាយការណ៍ជូនគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាតាមការតម្រូវ និងអនុវត្តកាតព្វកិច្ចពន្ធដារជូនរដ្ឋ តាមរយៈការកាន់បញ្ជីគណនេយ្យច្បាស់លាស់តាមគំរូណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

(ញ) សហការណ៍ និងផ្តល់ការឧបត្ថម្ភនានាដល់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសក្នុងកិច្ចដំណើរការរបស់តំបន់ និងមានទំនាក់ទំនងជិតស្និទ្ធជាមួយរដ្ឋអំណាចមូលដ្ឋានដើម្បី និងដោះស្រាយការងារដែលមានការពាក់ព័ន្ធ។

ដើម្បីធានាបាននូវការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសប្រកបភាពជោគជ័យ អ្នកអភិវឌ្ឍតំបន់ និងស្ថាប័នពាក់ព័ន្ធត្រូវមានការចូលរួមអនុវត្តច្បាប់ និងទទួលខុសត្រូវខ្ពស់។

## ៤. ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅខេត្តព្រះសីហនុ

### ៤.១. លក្ខណៈពិសេសនៃខេត្តព្រះសីហនុ

ខេត្តព្រះសីហនុ ជាខេត្តមានសក្តានុពលសេដ្ឋកិច្ចនៅប៉ែកខាងត្បូងនៃ

ប្រទេសកម្ពុជា ដែលត្រូវបានបង្កើតថ្មីនៅឆ្នាំ១៩៦៤។ ការបង្កើតក្រុងព្រះសីហនុ គឺដើម្បីរំឭកដល់ស្នាព្រះហស្តរបស់ព្រះបាទនរោត្តមសីហនុ ដោយមានឈ្មោះដើម "ក្រុងកំពង់សោម"។ ទៀតសោត ក្រុងព្រះសីហនុ ជាទីក្រុងដែលមានកំពង់ផែសមុទ្រធំបង្អស់របស់ប្រទេសកម្ពុជា ស្ថិតនៅពាក់កណ្តាលចន្លោះប្រទេសថៃនិងវៀតណាម ជាកន្លែងដែលគួរឱ្យចាប់អារម្មណ៍ខ្លាំងសម្រាប់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ។

ខេត្តព្រះសីហនុ ជាប៉ូលសេដ្ឋកិច្ចមួយក្នុងចំណោមប៉ូលសេដ្ឋកិច្ចទាំងបីនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីបីរបស់រាជរដ្ឋាភិបាលកម្ពុជា និងត្រូវបានកំណត់គោលដៅ ជាតំបន់សេដ្ឋកិច្ចពិសេសពហុបំណង នៅក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ២០១៥-២០២៥ ដោយសារខេត្តមានសក្តានុពលលើវិស័យទេសចរណ៍ ឧស្សាហកម្ម ពាណិជ្ជកម្ម[៤]។ បច្ចុប្បន្នខេត្តព្រះសីហនុមានស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ការគ្រប់គ្រងគ្រោះមហន្តរាយ ការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈក្រោមម្លប់សុខសន្តិភាព[៥]។

បច្ចុប្បន្នផ្លូវល្បឿនលឿនពីរាជធានីភ្នំពេញទៅខេត្តព្រះសីហនុបានបើកឱ្យដំណើរការក្នុងឆ្នាំ២០២២ ដែលមានប្រវែង ១៨៧.០៥គីឡូម៉ែត្រ ដោយចំណាយពេលត្រឹម២ទៅ២ម៉ោងនិង៣០នាទីប៉ុណ្ណោះ។

**៤.២. សាពឲ្យខាននៃការបឲ្យើតតំបន់សេដ្ឋកិច្ចពិសេស**

ដំណើរការប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេសរបស់ព្រះរាជាណាចក្រកម្ពុជា បច្ចុប្បន្ននេះ គឺពុំទាន់មានការរួមបញ្ចូលគ្នាតែមួយជាប្រព័ន្ធនៅក្នុងនយោបាយរដ្ឋនៅឡើយទេ។ បញ្ហាពិតប្រាកដនៃការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងដំណាក់កាលបច្ចុប្បន្ន គឺជាបញ្ហាផ្នែក ច្បាប់ សង្គម សេដ្ឋកិច្ច ហើយនិងបញ្ហាភូមិសាស្ត្រ។

នៅពេលមានបញ្ញត្តិ និងសេចក្តីសម្រេចរបស់រដ្ឋ ដែលផ្តល់ដល់ទីតាំងណាមួយ ឬទីតាំងមួយផ្សេងទៀតនូវ

[៤] ប្រវត្តិនិងការវិវត្តនៃការគ្រប់គ្រងដឹកនាំ ខេត្តព្រះសីហនុ ឆ្នាំ២០១៦។

[៥] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០១៧-២០១៩) ខេត្តព្រះសីហនុ។

របបតំបន់សេដ្ឋកិច្ចពិសេស ដោយមានឯកសារផ្លូវការមួយចំនួន ដែលប្រឆាំងពួកគេ ហើយធ្វើជាឧបសគ្គដល់ការងារនៃការបង្កើតនូវតំបន់សេដ្ឋកិច្ចពិសេស។

ការរស់រានៃតំបន់សេដ្ឋកិច្ចពិសេសនៅប្រទេសកម្ពុជា ការពិតសភាជាតិនិងព្រឹទ្ធសភាមាន "កាតព្វកិច្ច" ធ្វើការសម្រេច និងការអនុម័តច្បាប់ជាផ្លូវការ ដោយមតិភាគច្រើន (២ភាគ៣) ដែលមានការចុះលេខ ថ្ងៃទីខែឆ្នាំ "អំពីការបង្កើតនូវតំបន់ពាណិជ្ជកម្មពិសេស" តាមរយៈ "ព្រះរាជក្រឹត្យលេខ៣/នស/៩៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤" អំពីច្បាប់វិនិយោគនៅក្នុង ប្រទេសកម្ពុជា និង "ព្រះរាជក្រឹត្យលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ អំពីច្បាប់វិសោធនកម្មចំពោះច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា"[៦]។

ជាមួយគ្នានេះដែរ ការបង្កើតនិងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសនៅខេត្តព្រះសីហនុដោយអនុលោមទៅតាមច្បាប់ទាំងនោះ តំបន់សេដ្ឋកិច្ចពិសេសត្រូវបង្កើតនូវក្នុងគោលបំណងសម្រាប់ការទាក់ទាញពីអ្នកវិនិយោគបរទេស បច្ចេកវិទ្យាបរទេសនាំមុខ វិទ្យាសាស្ត្របច្ចេកទេស និងបទពិសោធន៍នៃការគ្រប់គ្រង ការអភិវឌ្ឍសក្ដានុពលនៃការនាំចេញ។ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសសម្រាប់ការវិនិយោគរបស់បរទេស និងសហគ្រាស ដែលមានបរទេសចូលរួម ដូចទៅះ

- ភាពងាយស្រួលនៃការចុះបញ្ជីសហគ្រាសជាមួយអ្នកវិនិយោគបរទេស។
- ការយកពន្ធដារទៅតាមអត្រាអនុគ្រោះ (រហូតដល់៥០%) ដែលបានកំណត់សម្រាប់អ្នកវិនិយោគបរទេសលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។
- ការបន្ធូរបន្ថយអត្រាបង់ពន្ធចំពោះការប្រើប្រាស់ដី និងធនធានធម្មជាតិផ្សេងៗទៀត។
- ការផ្តល់សិទ្ធិលើការជួលរយៈពេលវែងរហូតដល់៩៩ឆ្នាំ។
- ការបន្ធូរបន្ថយពន្ធគយ ឬមិនយកពន្ធគយលើការនាំទំនិញចេញនិងចូល។
- ការការពារនូវទ្រព្យសម្បត្តិក្រុមហ៊ុនសហគ្រាសដែលបានវិនិយោគ។

[៦] **ច្បាប់វិនិយោគទុននៃព្រះរាជាណាចក្រកម្ពុជា** ខែសីហា ឆ្នាំ១៩៩៤ និង ច្បាប់វិសោធនកម្មលើច្បាប់វិនិយោគទុននៃព្រះរាជាណាចក្រកម្ពុជា ខែមីនា ឆ្នាំ ២០០៣។

- ភាពងាយស្រួលនៃការឆ្លងកាត់ព្រំដែន ការចេញ-ចូលរបស់ពលរដ្ឋបរទេស ក្នុងនោះដោយមិនប្រើទិដ្ឋការ។

- សិទ្ធិអាចរកបានដោយមិនចាំបាច់អាជ្ញាប័ណ្ណនៃការនាំចេញនិងនាំចូលដែលបានពិនិត្យមើលនៅក្នុងច្បាប់សម្រាប់សហគ្រាសទាំងឡាយណាដែលជាកម្មសិទ្ធិទាំងមូលរបស់អ្នកវិនិយោគបរទេស ហើយព្រមទាំងសម្រាប់សហគ្រាសចំរុះ (រួមគ្នា) ដែលមានចំណែកវិនិយោគច្រើនជាង៣០%។ ចំណូលរូបិយវត្ថុរបស់សហគ្រាស ពីការនាំចេញនូវផលិតផលរបស់ខ្លួនស្ថិតនៅលើការប្រើប្រាស់ទាំងស្រុងរបស់ពួកគេ។

សម្រាប់ការអនុម័តនៃច្បាប់នេះ ជាទូទៅការបង្កើតនូវតំបន់សេដ្ឋកិច្ចពិសេស បានធ្វើឱ្យគ្មានសណ្តាប់ធ្នាប់នៃការចែកចាយការអនុគ្រោះ និង ការសន្យាតំបន់ផ្សេងទៀត។ នៅក្នុងលទ្ធផលដែលផ្តល់ដោយច្បាប់ ការអនុគ្រោះសម្រាប់តំបន់សេដ្ឋកិច្ចពិសេសមានទិដ្ឋភាពស្រគត់ស្រគំ។

នៅដើមឆ្នាំ២០០០ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចលើកទិសដៅសេដ្ឋកិច្ចយ៉ាងស៊ីជម្រៅនៅក្នុងគោលបំណងនៃការធ្វើឱ្យមានស្ថិរភាពសេដ្ឋកិច្ច ដូច្នេះការជ្រើសរើសយកបរិយាកាសសេរីភាពនៃអាជីវកម្មនៅលើកម្រិតដោយឡែកនៃតំបន់ភាគច្រើន ត្រូវបានកាត់ផ្តាច់នូវគំនិតរបស់ខ្លួន។ ចាប់ពីដើមឆ្នាំ២០០០មក ការអនុម័តច្បាប់នៃព្រះរាជណាចក្រកម្ពុជាសម្រាប់ការត្រួតពិនិត្យនូវសកម្មភាពនៃសេដ្ឋកិច្ចក្រៅប្រទេស មិនបានពិនិត្យមើលពីពេលកំណត់នៃការដាក់ពាក្យសុំចំពោះតំបន់សេដ្ឋកិច្ចពិសេសទេ។ ហើយទោះបី តាមកម្លាំងច្បាប់នៅក្នុងតំបន់ជាផ្លូវការ គ្មាននរណាលុបចោលក៏ដោយ ប៉ុន្តែអាជ្ញាធរពន្ធដារ អាចបកស្រាយថា ពួកគេបានអស់ឥទ្ធិពលដែលការពិតនឹងត្រូវបិទមួយផ្នែកនូវការអនុគ្រោះពន្ធ ដែលបានផ្តល់ដល់តំបន់សេដ្ឋកិច្ចពិសេសកាលពីពេលមុន។

ការដែលមិនអាចកំណត់បានបែបនេះ នៅក្នុងស្ថានភាពច្បាប់នៃតំបន់សេដ្ឋកិច្ចពិសេស និងធ្វើឱ្យមានការព្រួយបារម្ភរបស់អ្នកវិនិយោគបរទេស ហើយធ្វើការវាយតម្លៃនូវស្ថានភាពដែលកើតឡើង ដូចជាការងាកចេញ នៃគោលការណ៍រាជរដ្ឋាភិបាលចេញពីខ្សែបន្ទាត់

នៅលើការបង្កើតតំបន់សេដ្ឋកិច្ចពិសេស។ ជាមួយគ្នានេះដែរ សំណូមពររបស់ថ្នាក់ដឹកនាំរដ្ឋបាលនៃតំបន់ គឺការសុំជាផ្លូវការទៅនឹងរាជរដ្ឋាភិបាលឱ្យផ្តល់ការជានា ដល់សកម្មភាពពីដំបូង ដែលបាននាំមកដល់ក្នុងតំបន់សេដ្ឋកិច្ចពិសេសនូវប្រព័ន្ធអនុគ្រោះ ជួយជំរុញឱ្យមានប្រក្រតីភាពឡើងវិញគឺ ត្រូវធ្វើឡើងតាមរយៈសេចក្តីប្រកាសរបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយទាំងចុះលេខនិងចុះថ្ងៃខែឆ្នាំផង ស្តីអំពី "វិធានការខ្លះៗក្នុងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា" ដែលត្រូវអះអាងពីប្រតិបត្តិការនៅក្នុងតំបន់សម្រាប់សហគ្រាសបរទេស និង សហគ្រាសដែលវិនិយោគចំរុះជាមួយបរទេស ការរក្សាបាននូវការអនុគ្រោះដោយឡែកនៅក្នុងវិស័យសកម្មភាពសេដ្ឋកិច្ចក្រៅប្រទេសសម្រាប់សហគ្រាសកម្ពុជា ព្រមទាំងត្រូវត្រួតពិនិត្យមើលនូវការបន្ថែមការអនុគ្រោះរួមខ្លះៗ ដែលមានទិសដៅលើការបន្ធូរបន្ថយនូវហិរញ្ញប្បទានដល់គម្រោងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស (ការផ្តល់នូវថវិកា ឥណទានសម្រាប់គោលដៅទាំងនេះ ការបញ្ជូនទៅក្នុងមូលនិធិពិសេសនៃតំបន់សេដ្ឋកិច្ចពិសេស នូវធនធានមួយផ្នែកពីការផ្ទេរកម្មសិទ្ធិទៅឯកជន។ ការសម្រេចដាក់បញ្ញត្តិជួយជំរុញតំបន់ដោយឡែកដែលជាតំបន់នឹងមានការអភិវឌ្ឍច្រើន (ដូចជាខេត្តព្រះសីហនុ ខេត្តកំពត ខេត្តកោះកុង ខេត្តតាកែវ ខេត្តស្វាយរៀង) ចាប់ផ្តើមអនុវត្តការរៀបចំនូវយុទ្ធសាស្ត្រអភិវឌ្ឍទឹកដី និងគម្រោងវិនិយោគទុនដាក់លាក់ (CIP)។

### ៤.៣. វឌ្ឍនភាពនៃតំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ

តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ គឺជាតំបន់សហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មក្រៅប្រទេសដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងលើកកម្ពស់លក្ខខណ្ឌទីផ្សារ។ ជាពិសេសកំពង់ផែស្វយ័តក្រុងព្រះសីហនុមានរដ្ឋបាលឯករាជ្យ និងមានទីតាំងស្ថិតនៅក្រុងព្រះសីហនុដែលជាទីក្រុងកំពង់ផែអន្តរជាតិតែមួយគត់នៅកម្ពុជាចម្ងាយ៣គីឡូម៉ែត្រពីព្រលានយន្តហោះក្រុងព្រះសីហនុ និង១២គីឡូម៉ែត្រពីកំពង់ផែទឹកជ្រៅអន្តរជាតិក្រុងព្រះសីហនុ ជិតផ្លូវ

ជាតិលេខ៤ មានចម្ងាយប្រមាណ២១០ គីឡូម៉ែត្រពីភ្នំពេញប៉ុណ្ណោះ។

នៅឆ្នាំ២០១៨ ការនាំចេញរបស់តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុសម្រេចបានក្នុងទំហំជាទឹកប្រាក់ប្រមាណជាង ៣៧២លានដុល្លារអាមេរិក កើនឡើងប្រមាណ ៦៨% បើធៀបនឹងឆ្នាំ២០១៧ ដែលមានក្រុមហ៊ុនវិនិយោគត្រឹមចំនួន១៦១ក្រុមហ៊ុន ជាមួយនឹងដើមទុនវិនិយោគចុះបញ្ជីសរុបមានចំនួនជាង៩០០លានដុល្លារអាមេរិកនិងបានផ្តល់នូវការងារសម្រាប់កម្មករនិយោជិតជាង ២ម៉ឺន២ពាន់នាក់[៧]។ ក្នុងនោះ រោងចក្រផលិតសំខាន់ ដែលមាននៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ មានដូចជា រោងចក្រផលិតគ្រឿងអេឡិចត្រូនិក ខ្សែបង្ហុំអគ្គិសនីសំបកកង់រថយន្ត គ្រឿងបន្លាស់រថយន្តស៊ុមទូរទស្សន៍ សម្ភារបរិក្ខាបន្ទប់ទឹកផលិតក្តារប៉ាកេនិងក្តារបន្ទះ សម្ភារការិយាល័យរោងចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើង កាបូប និងវ៉ាលី និងរោងចក្រផលិតសម្ភារប្រើប្រាស់ជាច្រើនផ្សេងទៀតផងដែរ។

ក្នុងឆ្នាំ២០២៤ តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុបានទាក់ទាញសហគ្រាសបានចំនួន ២០២ មកពីជាង ១០ប្រទេស និងបង្កើតឱកាសការងារជាង ៣០,០០០កន្លែង និង៧%នៃការនាំចូលនិងនាំចេញសរុបរបស់ប្រទេស។ ទំហំនាំចេញពីតំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុមានចំនួន ១,៤៩៣ លានដុល្លារក្នុងអំឡុងខែមករាដល់វិច្ឆិកា។

តំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៨ រំពឹងថានឹងអាចទទួលសហគ្រាសរហូតដល់៣០០សហគ្រាស ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ដែលអាចបង្កើតការងាររហូតដល់ ១០០,០០០កន្លែងសម្រាប់អ្នកក្នុងស្រុក។

តំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុគឺជាតំបន់សេដ្ឋកិច្ចពិសេសមួយក្នុងចំណោមតំបន់សេដ្ឋកិច្ចពិសេសចំនួន២៦ ដែលមានរោងចក្រសរុបចំនួន

[៧] "សេចក្តីប្រកាសព័ត៌មានផ្លូវការរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា" ឆ្នាំ២០១៨។

៤៣១ដែលបង្កើតការងារបាន ១៨៣,៧០៣កន្លែង[៨]។

តំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុផ្តោតជាសំខាន់លើវិស័យដូចជា សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ គ្រឿងបន្លាស់រថយន្ត គ្រឿងអេឡិចត្រូនិក ការផលិតសំបកកង់រថយន្ត និងដំឡើងរថយន្ត និងកង់។ គិតត្រឹមខែតុលា ឆ្នាំ២០២៤ កម្ពុជាមានរោងចក្រចំនួន ១ ២៧៣ ដែលវិនិយោគដោយវិនិយោគិនចិន សរុបទឹកប្រាក់ចំនួន ៩,០៨ ពាន់លានដុល្លារ។

## ៥. សេចក្តីសន្និដ្ឋាន

ខេត្តព្រះសីហនុ ជាខេត្តដែលមានសក្តានុពលសេដ្ឋកិច្ច រួមមានកំពង់ផែទឹកជ្រៅ តំបន់សេដ្ឋកិច្ចពិសេស ព្រលានយន្តហោះអន្តរជាតិ តំបន់ឆ្នេរសមុទ្រ និងកោះធម្មជាតិដ៏ស្រស់ស្អាតជាច្រើន។ បច្ចុប្បន្នមានផ្លូវល្បឿនលឿនពីរាជធានីភ្នំពេញទៅខេត្តព្រះសីហនុ បង្កលក្ខណៈងាយស្រួលក្នុងការធ្វើដំណើរ។

តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ជាប៉ូលសេដ្ឋកិច្ចដ៏សំខាន់ ព្រោះជាតំបន់សេដ្ឋកិច្ចពិសេសពហុបំណងនៅក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា។

ដើម្បីឱ្យមានការទាក់ទាញនូវសក្តានុពលនៃអ្នកវិនិយោគចូលទៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ត្រូវបង្កើតនូវសេវាពិសេស និងការងារដែលនាំមកនូវលក្ខណៈបើកចំហរជាសារធារណៈ។ យើងអាចផ្សព្វផ្សាយដល់អ្នកវិនិយោគទុនជាមួយនឹងករណីពិសេស និងឧត្តមភាពផ្សេងៗគ្នានៃតំបន់បម្រើជាប្រភពគួរឱ្យជឿទុកចិត្ត ការអះអាងបន្ថែមនូវព័ត៌មានស្ថិតិជាក់លាក់ និងព័ត៌មាននៃការវាយតម្លៃពីអ្នកជំនាញដែលមានសារៈសំខាន់ចំបាច់សម្រាប់អ្នកវិនិយោគក្នុងស្រុក និងអ្នកវិនិយោគក្រៅស្រុក។

ការធ្វើពិពិធកម្មទីផ្សារនាំចេញរបស់កម្ពុជា ដែលនឹងរួមចំណែកសំខាន់ដល់ការពង្រឹងអធិបតេយ្យភាពជាតិ និងឯករាជ្យភាពនៃសេដ្ឋកិច្ចកម្ពុជា ព្រមទាំងឈានទៅសម្រេចបាននូវចក្ខុវិស័យឆ្នាំ២០៣០ (ប្រទេសចំណូលមធ្យម

[៨] របាយការណ៍របស់ក្រសួងពាណិជ្ជកម្មនៃប្រទេសកម្ពុជា ពីខែមករាដល់ខែវិច្ឆិកា ឆ្នាំ២០២៤។

កម្រិតខ្ពស់) និងឆ្នាំ២០៥០ (ប្រទេសចំណូលខ្ពស់)។ ដើម្បីសម្រេចបានផែនការខាងលើនេះ ការកំណត់ទិសដៅការងារពាណិជ្ជកម្មឆ្នាំ២០២០ឱ្យមានប្រសិទ្ធភាពខ្ពស់នោះ រួមមាន៖ ការកែទម្រង់ផ្ទៃក្នុង និងបន្តជំរុញសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាចូលក្នុងតំបន់និងពិភពលោក ការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈ និងពង្រឹងគុណភាពសេវាសាធារណៈ ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្ម ជំនាន់ទី៤ និងការរក្សាបាននូវសន្តិសុខស្បៀងអាហារ ស្ថិរភាពថ្លៃទំនិញនិងសេវាកម្ម ដើម្បីគាំទ្រនូវឧត្តមភាពប្រកួតប្រជែងរបស់កម្ពុជា។ ដូច្នេះ ការធ្វើពិពិធកម្មទីផ្សារ និងឱកាសការងារ សំដៅជំរុញការអភិវឌ្ឍ និងបែងចែកកំណើនសេដ្ឋកិច្ចជាតិប្រកបដោយប្រសិទ្ធភាព។

## ៦. ឯកសារយោង


១) អនុក្រឹត្យ លេខ១៤៧ អនក្រ.បក ស្តីពី “**ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ**” ឆ្នាំ២០០៥។

២) ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា “**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ**” ឆ្នាំ២០១៤-២០១៨។

៣) ឈឿន ប៊ុនធា “**ប្រសិទ្ធភាពនៃការបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅព្រះរាជាណាចក្រកម្ពុជា៖ ករណីសិក្សាខេត្តព្រះសីហនុ**” គម្រោងស្រាវជ្រាវឆ្នាំ២០១៩។

៤) Peter Warr និង Jayant Menon “**តំបន់សេដ្ឋកិច្ចពិសេសប្រទេសកម្ពុជា**” ឆ្នាំ២០១៥។

៥) **ប្រវត្តិនិងការវិវត្តនៃការគ្រប់គ្រងដឹកនាំខេត្តព្រះសីហនុ** ឆ្នាំ២០១៦។

៦) **សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល** (២០១៧-២០១៩) ខេត្តព្រះសីហនុ។

៧) https://en.wikipedia.org/wiki/ Sihanoukville_Province

៨) http://www.akp.gov.kh/?p=79956

៩) https://www.canbypublications.com/sihanoukville-cambodia/sihanoukville

១០) https://traincambodia.com/timetable-prices

# ឧបសម្ព័ន្ធ

## ផែនទីរដ្ឋបាលខេត្តព្រះសីហនុ






*រចនាសម្ព័ន្ធគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជា។*




*ទីតាំងអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។*



សួនឧស្សាហកម្មនៃតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ។



សកម្មភាពពាណិជ្ជកម្មនៅក្នុងទីក្រុងនៃតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ។



*សកម្មភាពសាងសង់សំណង់ និងគម្រោងវិនិយោគធំៗនៅក្រុងព្រះសីហនុ។*



*ក្រុងព្រះសីហនុ ត្រូវបានជ្រើសរើសជាកន្លែងរៀបចំវេទិកាទេសចរណ៍អាស៊ាន២០២២*
*ដោយសារសម្បទាទេសចរណ៍សមស្រប។*



*ហេដ្ឋារចនាសម្ព័ន្ធ និង គម្រោងវិនិយោគក្រុងព្រះសីហនុ សក្ដិសមខេត្តជាប់មាត់សមុទ្ររបស់កម្ពុជា។*



*សមិទ្ធិផលហេដ្ឋារចនាសម្ព័ន្ធធំៗដែលនឹងជំរុញឱ្យក្រុងព្រះសីហនុក្លាយជាតំបន់សេដ្ឋកិច្ចពហុបំណង។*



គោលបំណងប្រែក្លាយក្រុងព្រះសីហនុឱ្យក្លាយជាតំបន់សេដ្ឋកិច្ចពហុបំណង
រដ្ឋាភិបាលកម្ពុជា ជាពិសេសអាជ្ញាធរខេត្តបាននិងកំពុងសាងសង់ហេដ្ឋារចនាសម្ព័ន្ធធំៗ
ជាច្រើនក្នុងខេត្តព្រះសីហនុ។




គម្រោងខ្លះបានបញ្ចប់ការសាងសង់រួចហើយ ខ្លះកំពុងសាងសង់ ហើយខ្លះទៀតគ្រោង
នឹងសាងសង់។



ផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ ជាផ្លូវល្បឿនលឿនដំបូងបង្អស់នៅកម្ពុជា ត្រូវបាន ដាក់ឱ្យដំណើរការនៅឆ្នាំ២០២២ ដោយចំណាយថវិកាសាងសង់ប្រមាណ ២ពាន់លាន ដុល្លារអាមេរិក អភិវឌ្ឍន៍ដោយក្រុមហ៊ុនសាជីវកម្មស្ពាន និងថ្នល់ចិន (CRBC)។




កំពង់ផែទឹកជ្រៅ ក្រោមកិច្ចសហប្រតិបត្តិការរវាងប្រទេសជប៉ុន និងរាជរដ្ឋាភិបាលកម្ពុជា ខេត្តព្រះសីហនុក៏កំពុងតែពង្រីកកំពង់ផែទឹកជ្រៅដ៏ធំសម្បើម ដែលអាចស្រូបយកទំនិញ នាំចេញ-នាំចូលក្នុងប្រទេសបានដល់៧០ភាគរយ។



ព្រលានយន្តហោះអន្តរជាតិកងកេង ខេត្តព្រះសីហនុ ក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុនបាពាំង។




កំណែលម្អផ្លូវខេត្តនានា៖ ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្នុងក្រុងព្រះសីហនុ។



*អាងប្រព្រឹត្តកម្មទឹកកខ្វក់ ដើម្បីកាត់បន្ថយទឹកកខ្វក់ហូរចូលសមុទ្រខេត្តព្រះសីហនុ។*



*ទីលានចាក់សំរាម ដែលជាទីលានចាក់សំរាមថ្មីលើផ្ទៃដីប្រមាណ ១៧ហិកតា ក្នុងខេត្តព្រះសីហនុ។*